**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប មានប្រសាសន៍ថា ការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលវែង ដល់អតីតមេដឹកនាំគណបក្សប្រឆាំង គឺជាការគួរឱ្យរន្ធត់ចិត្ត

ទីក្រុងហ្សឺណែវ (០៥ មីនា ២០២១) – ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានមានប្រសាសន៍នៅថ្ងៃនេះថា ពួកគាត់សម្តែងនូវការសោកស្តាយចំពោះការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលមិនសមាមាត្រ ដល់មេដឹកនាំជាន់ខ្ពស់និរទេសខ្លួននៃគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ ហើយបានអំពាវនាវឱ្យរដ្ឋាភិបាលការពារសេរីភាពចងក្រងសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ដើម្បីធានាដល់ដំណើរការប្រជាធិបតេយ្យ និងសកម្មភាពនយោបាយ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ អាចនឹងដកហូតសិទ្ធិរបស់មេដឹកនាំជាន់ខ្ពស់ទាំងនោះ ក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ។ ចាប់តាំងពីខែមិថុនា ឆ្នាំ២០១៩ មក មានមនុស្សច្រើនជាង ១៥០ នាក់ ដែលជាប់ទាក់ទងជាមួយគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងស្ថិតក្នុងដំណើរការនីតិវិធីរបស់តុលាការ។

នៅថ្ងៃទី០១ ខែមីនា តុលាការបានកាត់ទោសកំបាំងមុខមេដឹកនាំជាន់ខ្ពស់ប្រាំបួនរូបនៃអតីតគណបក្សសង្គ្រោះជាតិពីបទចោទទាក់ទងនឹង "ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ" និង" បទឧបឃាត និងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា" តាមមាត្រា២៧ និងមាត្រា៤៥១ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ នេះទាក់ទងទៅនឹងផែនការរបស់ពួកគេ ក្នុងការវិលត្រឡប់មកប្រទេសវិញ ដើម្បីចូលរួមក្នុងជីវភាពនយោបាយនៅកម្ពុជា ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើបណ្តាញសង្គមក្នុងខែតុលា ឆ្នាំ២០១៩ ។ ក្រុមអ្នកជំនាញមានកង្វល់ជាខ្លាំងដែលថា ការបង្ហោះនៅហ្វេសប៊ុករបស់លោក សម រង្ស៊ី និងឃ្លីបវីដេអូរបស់ជនជាប់ចោទទាំងប្រាំបួនរូប ត្រូវបានគេចាត់ទុកថាជាបទឧក្រិដ្ឋ ។

ក្រុមអ្នកជំនាញ អ.ស.ប បានមានប្រសាសន៍ថា ដំណើរការជំនុំជម្រះទាំងមូល មានភាពមិនប្រក្រតី និងបំពានយ៉ាងជាក់ច្បាស់ទៅនឹងច្បាប់អន្តរជាតិ រួមទាំង ការជំនុំជម្រះដែលមិនបានប្រព្រឹត្តទៅជាសាធារណៈ។

ក្រុមអ្នកជំនាញ បានអំពាវនាវឱ្យរដ្ឋាភិបាលផ្តល់សិទ្ធិធ្វើនយោបាយឱ្យពួកគេឡើងវិញ និងធានាឱ្យគណបក្សនយោបាយទាំងអស់ មានឱកាសស្មើគ្នា ដើម្បីចូលរួមក្នុងជីវភាពនយោបាយ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ធានាការពារសេរីភាពចងក្រងសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ដោយសារថា សេរីភាពទាំងនេះគឺជាសរសរស្តម្ភនៃសង្គមប្រជាធិបតេយ្យ និងជាអ្នកធានាការពារដល់ដំណើរការបោះឆ្នោតប្រកបដោយសេរីនិងយុត្តិធម៌។ ការផ្តន្ទាទោសមេដឹកនាំគណបក្សប្រឆាំងទាំងប្រាំបួនរូប ដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ និងដោយអវត្តមានជនជាប់ចោទ បានលើកឡើងជាកង្វល់ខ្លាំងអំពីភាពចុះសម្រុងនឹងគ្នានៃសេចក្តីសម្រេចនេះទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង"។

លោក សម រង្ស៊ី អតីតមេដឹកនាំគណបក្សសង្គ្រោះជាតិ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២៥ ឆ្នាំ និងដកហូតសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត។ មេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេល ២២ ឆ្នាំ (រួមមាន អ្នកស្រី មូរ សុខហួរ និងលោក អេង ឆៃអ៊ាង) និងរយៈពេល ២០ ឆ្នាំ (រួមមាន អ្នកស្រី ជូឡុង សូមូរ៉ា លោកម៉ែន សុថាវរិន្ទ្រ លោក អ៊ូ ច័ន្ទរិទ្ធ លោក ហូ វ៉ាន់ លោក ឡុង រី និងលោក នុត រំដួល) ។ មេដឹកនាំទាំងនេះក៏ត្រូវបានតុលាការបង្គាប់ឱ្យបង់ប្រាក់ចំនួន ១.៨០០ លានរៀល (ប្រហែលជា ៤២.៥០០ ដុល្លារ) ទៅឱ្យរដ្ឋាភិបាលផងដែរ។

"យើងមានការរន្ធត់ចិត្តចំពោះការកាត់ទោសជនជាប់ចោទឱ្យជាប់ពន្ធនាគាររយៈពេលវែង និងមិនសមាមាត្រ ដែលខ្វះមូលដ្ឋានច្បាប់ច្បាស់លាស់។" ក្រុមអ្នកជំនាញបានមានប្រសាសន៍ដូចនេះ ដោយបញ្ជាក់បន្ថែមទៀតថា មិនមានភ័ស្តុតាងគួរឱ្យជឿទុកចិត្តបាន បង្ហាញពីរបៀបដែលការរិះគន់របស់ជនជាប់ចោទចំពោះរដ្ឋាភិបាលបង្កឱ្យមាន "បទឧបឃាត" ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌនោះ។

កន្លងមក អ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានលើកឡើងនូវកង្វល់ខ្លាំងអំពីការធ្លាក់ចុះនៃលំហប្រជាធិបតេយ្យនៅកម្ពុជា ក៏ដូចជា របៀបដែលការជំនុំជម្រះទ្រង់ទ្រាយធំ ដែលដៅទៅលើបុគ្គលទាំងឡាយដែលជាប់ទាក់ទងជាមួយគណបក្សសង្គ្រោះជាតិ ទំនងជាដោយសារហេតុផលនយោបាយ។

**ចប់**

** **អ្នកជំនាញ អ.ស.ប ៖ លោកស្រី រ៉ូណា ស្ម៊ីត** (Ms Rhona Smith) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក **ដេវីដ កៃ** (Mr David Kaye) អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរី*

ភាពក្នុងការបញ្ចេញមតិ និង លោក **ឌី ហ្គោ ហ្គារស្យា-សាយ៉ាន** (Mr Diego García-Sayán) អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី។ លោក **ក្លេមែនត៍ នីយ៉ាលេតសូស្ស៊ី វ៉ូលេ** (Clement Nyaletsossi Voule) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិក្នុងការជួបជុំដោយសន្តិវិធី និងសិទ្ធិសមាគម។ អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប នីតិវិធីពិសេសគឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ក្រុមអ្នកជំនាញនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយមិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ខ្លួនឡើយ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ។

សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស — កម្ពុជា

សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងលោក **ម៉ាស័មូដ ហ្គារហ្គា** (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬអ៊ីម៉ែល៖ mgarga@ohchr.org) ឬលោក **ណាវីដ អាម៉េដ** (Mr Naveed Ahmad) តាមរយៈអ៊ីម៉ែល៖ Nahmed@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទងលោក **រេនណាតូ ឌឺ ស៊ូហ្សា** (Renato de Souza) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩៨៥៥ ឬ អ៊ីម៉ែល៖ rrosariodesouza@ohchr.org)

តាមដានព័ត៌មានទាក់ទងនឹងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់អ.ស.ប តាមបណ្តាញទ្វីធទ័រ Twitter@UN_SPExperts

តើអ្នកខ្វល់អំពីពិភពលោកដែលយើងរស់នៅ ឬទេ?

**ដូច្នេះ ក្រោកឈរ ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។**

#Standup4humanrights

ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org